អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក

ជាន់ទី១២ អាគារ Exchange Square
ផ្លូវលេខ១០៦ កែងផ្លូវលេខ៦១
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

AIA.COM.KH

# សេចក្តីប្រកាសសារព័ត៌មាន

## គម្រោងទីលានបាល់ទាត់១០០ របស់ អេ អាយ អេ ខេមបូឌា បានបញ្ចប់ជាមួយការបរិច្ចាគសម្ភារៈបាល់ទាត់ច្រើនបំផុត

**សៀមរាប ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ –** វគ្គចុងក្រោយនៃគម្រោងទីលានបាល់ទាត់១០០ របស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") បានធ្វើឡើងក្នុងថ្ងៃនេះផ្ទាល់ នៅខេត្តសៀមរាបដោយនាំមកនូវភាពជោគជ័យក្នុងការបំពាក់សម្ភារៈបាល់ទាត់ដល់សាលាបឋមសិក្សាចំនួន១០០សាលាទូទាំងប្រទេសកម្ពុជា ដែលសាលានិមួយៗទទួលបាន បង្គោលទី២ ក្តារអមតារាង៤ បាល់១០គ្រាប់ អាវកាក់៣០ និងកោណហាត់បាល់៤០។ គម្រោងនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយឲ្យកុមារនៅកម្ពុជាស្រឡាញ់វិស័យកីឡា ដែលស្របគ្នាជាមួយនឹងការប្តេជ្ញារបស់ អេ អាយ អេ ក្នុងការជួយឲ្យប្រជាជនទទួលបានសុខភាព និងជីវិតកាន់តែប្រសើរ។

គម្រោងទីលានបាល់ទាត់១០០ ត្រូវបានប្រកាសតាំងពីខែមករាដើមឆ្នាំនេះ ក្នុងស្មារតីអបអរខួប១០០ឆ្នាំរបស់សម្ព័ន្ធ អេ អាយ អេ ដោយមានគោលបំណងបរិច្ចាគសម្ភារៈបាល់ទាត់ដល់សាលាបឋមសិក្សាចំនួន១០០សាលា នៅទូទាំងប្រទេសកម្ពុជា។ អតិថិជន អេ អាយ អេ បុគ្គលិក ទីប្រឹក្សាផែនការជីវិត និងសាធារណៈជនជាច្រើនទៀត បានចូលរួមការអបអរនោះ ក្រោមប្រធានបទ«១០០ឆ្នាំដើម្បីការប្តេជ្ញា១» និងចូលរួមលើកកម្ពស់ការរស់នៅដោយសកម្ម និងប្រកបដោយសុខភាពកាន់តែល្អ។ ចាប់តាំងពីថ្ងៃនោះមក សម្ព័ន្ធ អេ អាយ អេ ទាំងមូល បានរៀបចំព្រឹត្តិការណ៍ជាច្រើនផ្សេងទៀតទូទាំងទីផ្សារទាំង១៨របស់ខ្លួន ដើម្បីអបអរដំណើរអាជីវកម្មពេញ១០០ឆ្នាំ ចាប់តាំងពីការកកើតយ៉ាងសាមញ្ញដំបូងនៅទីក្រុងសៀងហៃ រហូតបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតធំជាងគេបំផុតនៅលើពិភពលោក។[១]

លោកស្រី ខៀវ វរៈច័ន្ទ នាយិកាផ្នែកទីផ្សាររបស់ អេ អាយ អេ ខេមបូឌា ដែលទទួលបន្ទុកលើដំណើរការគម្រោងទីលានបាល់ទាត់១០០ បានមានប្រសាសន៍ថា «ខួប១០០ឆ្នាំរបស់យើង មិនត្រឹមតែប្រារព្ធឡើងដើម្បីក្រឡេកមើលលើប្រវត្តិសាស្ត្ររបស់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីសម្លឹងឆ្ពោះទៅរកអនាគត ហើយបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងក្នុងការជួយឲ្យប្រជាពលរដ្ឋរស់នៅមានជីវិតកាន់តែប្រសើរឡើង។ ដោយសារតែគំនិតផ្តួចផ្តើមនៃគម្រោងនេះ កុមាររាប់ពាន់នាក់នៅទូទាំងកម្ពុជាទទួលបាន និងអាចប្រើប្រាស់សម្ភារៈបាល់ទាត់ ដែលធ្វើឲ្យខ្ញុំ និងក្រុមការងារទាំងអស់មានមោទនភាពយ៉ាងខ្លាំង»។

ពិធីចែកសម្ភារៈបាល់ទាត់នៃគម្រោងទីលានបាល់ទាត់១០០ ដ៏ធំ និងចុងក្រោយនេះ ទទួលបានការចូលរួមពីអ្នកតំណាងនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ព្រមទាំងសិស្សានុសិស្ស អ្នកគ្រូ លោកគ្រូ នាយក នាយិកាជាច្រើននាក់ដែលពីសាលាចំនួន១៤ នៅខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ទីប្រឹក្សាផែនការជីវិត អេ អាយ អេ ថ្នាក់គ្រប់គ្រង និងបុគ្គលិកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ព្រមទាំងសមាជិកក្រុមអ្នកគាំទ្រនៅកម្ពុជាជាផ្លូវការសម្រាប់ក្លិបបាល់ទាត់ Tottenham Hotspur ដែលជាដៃគូសកលរបស់ អេ អាយ អេ។

---

[១] ដោយយោងលើទីផ្សារមូលធននីយកម្ម *ប្រភព៖ Bloomberg ២០ មិនា ២០១៩*

លោកស្រី Pauline Teoh ថ្នាក់ដឹកនាំរបស់ អេ អាយ អេ ខេមបូឌា បានមានប្រសាសន៍ថា «វាជាថ្ងៃដ៏រីករាយសម្រាប់អ្នកទាំងអស់គ្នានៅ អេ អាយ អេ ខេមបូឌា ដែលយើងបានសម្រេចដោយជោគជ័យនូវគម្រោងទីលានបាល់ទាត់១០០ ក្នុងខេត្តសៀមរាបនេះ។ ក្រុមការងារទាំងអស់របស់យើង បានខិតខំធ្វើការរួមគ្នាយ៉ាងយកចិត្តទុកដាក់ ដើម្បីធ្វើឲ្យគម្រោងនេះក្លាយជាការពិត។ ការជួយផ្សព្វផ្សាយសារដ៏មានសារៈសំខាន់សម្រាប់ការរស់នៅដោយមានសុខភាពល្អ និងអំពីការចូលរួមក្នុងវិស័យកីឡា គឺជាការងារចម្បងនៃបេសកកម្មរបស់ អេ អាយ អេ។ ដូច្នេះយើងសង្ឃឹមថាគម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កុមារកម្ពុជាតទៅមុខជាច្រើនឆ្នាំបន្ថែមទៀត»។

គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់កុមាររាប់ពាន់នាក់នៅក្នុងសាលាបឋមសិក្សា និងសហគមន៍របស់ពួកគេនៅទូទាំងប្រទេស ដែលនេះបន្តជំរុញឲ្យ អេ អាយ អេ ខេមបូឌា នៅតែជាក្រុមហ៊ុនឈានមុខគេក្នុងការជួយយុវជនកម្ពុជាឲ្យចាប់យកបែបផែនរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ៕

**អំពី អេ អាយ អេ ខេមបូឌា**

អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") គឺជាបុត្រសម្ព័ន្ធ និងជាកម្មសិទ្ធិទាំងស្រុងរបស់ AIA Group Limited ("AIA") ដែលជាសម្ព័ន្ធក្រុមហ៊ុនធានារ៉ាប់រងជីវិតធំជាងគេបំផុតនៅលើពិភពលោកដោយយោងតាមទីផ្សារមូលធននីយកម្ម។

សម្ព័ន្ធ AIA មានវត្តមាននៅក្នុងទីផ្សារចំនួន១៨នៅអាស៊ីប៉ាស៊ីហ្វិក ដែលក្នុងនោះមានសាខា និងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិទាំងស្រុង នៅហុងកុង ថៃ សិង្ហបុរី ម៉ាឡេស៊ី ចិន កូរ៉េ ហ្វីលីពីន អូស្ត្រាលី ឥណ្ឌូនេស៊ី តៃវ៉ាន់ វៀតណាម ណូវែលហ្សេឡង់ ម៉ាកាវ ប្រ៊ុយណេ កម្ពុជា ព្រមទាំងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិ៩៧ភាគរយនៅសិរីលង្កា ក្រុមហ៊ុនសម្ព័ន្ធអាជីវកម្ម៤៩ភាគរយនៅឥណ្ឌូនេស៊ី និងការិយាល័យតំណាងនៅមីយ៉ាន់ម៉ា។ AIA គឺជាក្រុមហ៊ុននាំមុខទីផ្សារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (លើកលែងជប៉ុន) ដោយយោងលើបុព្វលាភធានារ៉ាប់រងជីវិត និងជាក្រុមហ៊ុនឈានមុខគេនៅក្នុងទីផ្សារភាគច្រើនរបស់ខ្លួន។ AIA មានទ្រព្យសរុប២៣០ពាន់លានដុល្លាអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ តាមរយៈបណ្តាញដ៏ទូលំទូលាយនៃភ្នាក់ងារ ដៃគូ និងធនធានមនុស្សនានាទូទាំងអាស៊ីប៉ាស៊ីហ្វិក AIA បម្រើម្ចាស់បណ្ណសន្យាធានារ៉ាប់រងច្រើនជាង៣៣លានបណ្ណ និងសមាជិកទទួលអត្ថប្រយោជន៍ធានារ៉ាប់រងតាមក្រុមហ៊ុននានាច្រើនជាង១៦លាននាក់។

អេ អាយ អេ ខេមបូឌា ផ្តល់ជូននូវដំណោះស្រាយ និងសេវាកម្មធានារ៉ាប់រងជីវិតឈានមុខគេក្នុងទីផ្សារ ដើម្បីបំពេញតម្រូវការលើការការពារ និងការសន្សំរយៈពេលវែង របស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា។ អេ អាយ អេ ខេមបូឌា ប្តេជ្ញាចូលរួមលើកកំពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៃព្រះរាជាណាចក្រកម្ពុជាឲ្យបានយូរអង្វែង និងជួយឲ្យប្រជាជនខ្មែរទទួលបានសុខភាព និងជីវិតកាន់តែប្រសើរ។

**ទំនាក់ទំនងសារព័ត៌មាន**

ហាក់ បញ្ញារ័ត្ន
ប្រធានផ្នែកទំនាក់ទំនងសាធារណៈ
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
០១៦/០១៧ ៣៦៩ ១៥៥
Panharath.Hak@aia.com